# ការសិក្សាស្រាវជ្រាវរុករកស្ថានីយបុរាណ
# ក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ
## (តចប់)

ដោយ : **បណ្ឌិត ផុន កសិកា**
*ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ការសិក្សាស្រាវជ្រាវនិងរុករកស្ថានីយបុរាណវត្ថុ ផ្តល់នូវវិភាគទានជាព័ត៌មានដ៏មានតម្លៃសម្រាប់បេតិកភណ្ឌវប្បធម៌។ ការរកឃើញស្ថានីយបុរាណនានាគឺជាប្រភពមួយផ្សេងទៀត ដែលអាចប្រើប្រាស់បានសម្រាប់កសាងប្រវត្តិសាស្ត្ររបស់ប្រទេសនីមួយៗ។ លក្ខខណ្ឌនានានៃភាពគង់វង្សដែលមាននៅក្នុងស្ថានីយ គឺមានសារសំខាន់ ពិសេសបំផុតដែលក្រុមអ្នកជំនាញបុរាណវត្ថុវិទ្យាអាចរុករកឃើញស្ថានីយនិងសារសំខាន់របស់ស្ថានីយ។ ភាគច្រើននៃការសិក្សាខាងបុរាណវត្ថុវិទ្យា គឺធ្វើការវិភាគលើបុរាណវត្ថុសិល្បៈ និងសំណល់វត្ថុបុរាណ វត្ថុបរិស្ថានធម្មជាតិដែលគេបានរកឃើញនៅក្នុងស្ថានីយ ព្រមទាំងសិក្សាអំពីទិដ្ឋភាពជុំវិញស្ថានីយ។ ការងារដំបូងរបស់បុរាណវត្ថុវិទ្យា ត្រូវធ្វើការរុករកនូវស្ថានីយបុរាណ ឱ្យឃើញច្រើនតាមលទ្ធភាពដែលអាចទៅធ្វើបាន និងធ្វើផែនទីកំណត់ទីតាំងឱ្យបានមុនការបំផ្លាញនានា។*

*ដើម្បីដំណើរការងារឱ្យបានសម្រេចជោគជ័យ ក្រុមអ្នកជំនាញបុរាណវត្ថុវិទ្យាជាច្រើន ក៏ពឹងផ្អែកទៅលើបច្ចេកវិទ្យានិងឧបករណ៍ស្រាវជ្រាវ ដើម្បីជួយដល់ការស្រាវជ្រាវរុករកស្ថានីយបុរាណ។*

*អត្ថបទស្រាវជ្រាវមួយនេះទទួលបានលទ្ធផលពីការចុះសិក្សាស្រាវជ្រាវរុករកស្ថានីយបុរាណ ប្រាសាទបុរាណទីទួលបុរាណ ដែលជាភូមិដ្ឋានមនុស្សរស់នៅ ត្រពាំងបុរាណនិងវត្ថុបុរាណ ដែលមាននៅក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ការសិក្សាស្រាវជ្រាវធ្វើឡើងនៅឆ្នាំ២០០៧ ដែលពេលនោះរាជរដ្ឋាភិបាលមិនទាន់បង្កើតស្រុកតាំងគោកនៅឡើយទេ។ ឃុំមួយចំនួនដែលស្ថិតក្នុងស្រុកតាំងគោកបច្ចុប្បន្នគឺជាអតីតឃុំដែលជារចនសម្ព័ន្ធស្រុកបារាយណ៍។*

*ការសិក្សាស្រាវជ្រាវនេះបានប្រើវិធីសាស្ត្របែបបុរាណវិទ្យា គូបង់បាតស្ថានីយធ្វើផែនទីតាំងស្ថានីយ ធ្វើសម្ភាសន៍ជាមួយអ្នកស្រុកចាស់ទុំដែលរស់នៅជិតស្ថានីយ*

បុរាណ។ ការសិក្សាស្រាវជ្រាវនេះក៏ប្រើរូបថតលើអាកាស តាមរយៈ Google Earth និងផែនទីជាឧបករណ៍និងជាមគ្គុទេសក៍សំខាន់ដែលបង្ហាញពីព័ត៌មានអត្តសញ្ញាណស្ថានីយ។ ការសិក្សាស្រាវជ្រាវអំពីប្រាសាទបុរាណ ទីទួលបុរាណ និងស្ថានីយបុរាណផ្សេងទៀតក៏ច្រើនពឹងផ្អែកលើឯកសាររបស់លោក Etienne Aymonier (1900)[1] និងលោក Lunet de Lajonquière (1902)[2] ដែលបាន ចុះសិក្សានិងចុះបញ្ជីប្រាសាទក្នុងប្រទេសកម្ពុជាជាច្រើន។ ទោះយ៉ាងណា ឯកសារទាំងពីរនេះមិនមានប្រាសាទ ទួលគ្រឹះប្រាសាទ និងស្ថានីយបុរាណច្រើននោះទេ លើកលែង គុកនគរ ប្រាសាទត្នោតជុំ (ប្រាសាទត្នោតជុំខាងលិច និង ប្រាសាទត្នោតជុំខាងជើង) វត្តជ្រលង វត្តបារាយណ៍។

ការសិក្សាស្រាវជ្រាវនេះនឹងបង្ហាញ ព្រមទាំងកំណត់បាននូវប្រាសាទមួយចំនួន ព្រមទាំងគ្រឹះប្រាសាទ ក៏ដូចជាស្ថានីយបុរាណជាច្រើនទៀត ក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ។

---

[1] Aymonier, Etinne., Le Cambodge I Le Royume Actuel, Paris, 1900

[2] Lajonquière, E. Lunet., Invenaire Descriptif des Monuments du Cambodge, Tome I, 1902.

## ទីតាំងភូមិសាស្ត្រ

ស្រុកបារាយណ៍[3]នៃខេត្តកំពង់ធំ មានឃុំចំនួន១៨ជារចនាសម្ព័ន្ធ ដូចជា : ឃុំបាក់ស្នា ឃុំក្រវ៉ា ឃុំគគីធំ ឃុំចើងដើង ឃុំបល្ល័ង្គ ឃុំត្នោតជុំ ឃុំចុងដូង ឃុំបឹង ឃុំបារាយណ៍ ឃុំឈូក ឃុំទ្រៀល ឃុំស្រឡៅ ឃុំជ្រលង ឃុំអណ្តូងពោធិ៍ ឃុំសូយោង ឃុំប្រនៀង ឃុំស្វាយភ្លើង និងឃុំពង្រ។




ផែនទីស្រុកបារាយណ៍ ខេត្តកំពង់ធំ (ឆ្នាំ២០០៧)

[3] ការសិក្សាស្រាវជ្រាវបានអនុវត្តក្នុងឆ្នាំ២០០៧។ បន្ទាប់ពីរដ្ឋាភិបាលកម្ពុជាបង្កើតស្រុកតាំងគោក ឃុំមួយចំនួនបានកាត់ចូលក្នុងស្រុកតាំងគោក (អនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃអង្គារ ៣កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតស្រុកតាំងគោក នៃខេត្តកំពង់ធំ) ដូចជាឃុំពង្រ ឃុំប្រនាង ឃុំជ្រលង ឃុំទ្រាល ឃុំស្រឡៅ ឃុំសូយោង ឃុំស្វាយភ្លើង និងឃុំអណ្តូងពោធិ៍។

## លទ្ធផលនៃការសិក្សាស្រាវជ្រាវ៖

### ២៣. ទួលតាហេវ និងទួលតាពេជ

ទួលតាពេជស្ថិតនៅខាងកើតទួលតាហេវ។ ទួលទាំងពីរស្ថិតនៅក្នុងឃុំបារាយណ៍ក្បែរអូរថ្មីមួយដែលគេជីកនៅឆ្នាំ១៩៨១។ ទួលតាពេជ ជាទួលដែលធ្លាប់ត្រូវបានគេជីករកវត្ថុបុរាណ ជាហេតុបន្សល់នូវស្លាកស្នាមបំណែកឥដ្ឋ និងរណ្ដៅកំណាយនៅរហូតដល់បច្ចុប្បន្ន។ តាមព័ត៌មានអ្នកស្រុកបានឱ្យដឹងថា ទួលនេះធ្លាប់ធ្វើជាឡដុតឥដ្ឋ។

រីឯទួលតាហេវ តាមព័ត៌មានបានឱ្យដឹងថា ទួលនេះពុំទាន់រងនូវការជីកកកាយឡើយ។ សព្វថ្ងៃប្រជាជន ប្រើប្រាស់ទួលនេះសម្រាប់បញ្ចុះសព។



បំណែកថ្មនៅក្នុងវត្តបារាយណ៍ដែលយកមកពីទួលតាពេជ



ទិដ្ឋភាពផ្នូរនៅលើទួលតាហេវ



ទួលតាពេជ



ស្នាមរណ្ដៅជីក និងឥដ្ឋនៅលើទួលតាពេជ

### ២៤. គុក

គុក ស្ថិតនៅក្នុងភូមិផ្លូវទ្រៀស (ផ្លូវទទឹង) ក្នុងឃុំឈូកខ្សាច់។ គុកនេះបានទទួលរងនូវការជីករកវត្ថុបុរាណក្នុងសម័យរដ្ឋកម្ពុជា។ តាមព័ត៌មានអ្នកភូមិបានឱ្យដឹងថា មុនការជីកកាយ ស៊ុមទ្វារពីមុនទ្រេតទៅកើតឆៀងខាងត្បូង។ មួយឆ្នាំក្រោយមកវាក៏ងើបត្រង់ឡើងវិញ (ប្រហែលដោយសារស្រុតដី)។ នៅលើទួលមានទម្រប់ដិមាមួយយ៉ាងធំ សន្ទឹកបបឋមសិលា ដែលគេយកមកដាក់បណ្ដុបលើទម្រប់ដិមា។

តាមរយៈការពិនិត្យទិដ្ឋភាពរបស់គុក គុកនេះសង់បែរមុខទៅទិសខាងកើត មានគូទឹកព័ទ្ធជុំវិញ។ ធ្លាប់មានអ្នកជីកប្រឡាយបំគូទឹកផ្នែកខាងលិច។ គុកមានផ្លូវនិងច្រកចូលពីទិសខាងកើត។ មានត្រពាំងធំមួយនៅខាងកើតគុកនេះ។ ប្រជាជនបានបន្តប្រើគុកនេះសម្រាប់ធ្វើបុណ្យក្នុងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ។



ទិដ្ឋភាពគុកមើលពីចម្ងាយ



ស៊ុមទ្វារគុក

## ២៥. ទួលស្តេចផ្អុំ

ទួលស្តេចផ្អុំ ស្ថិតនៅប្រមាណ៣០០ ម៉ែត្រពីវត្តពោធិ៍ស្តេចផ្អុំ ដែលស្ថិតនៅក្នុងឃុំឈូកខ្សាច់។ តាមរយៈទិដ្ឋភាពខាងក្រៅ យើងពុំអាចមើលឃើញរូបរាងទួលច្បាស់លាស់ទេ ក្រៅពីស្លាកស្នាមត្រពាំងធំមួយនៅជាប់នឹងទួលនោះ និងមានថ្មភក់មួយចំនួននៅលើទួលក្បែរគល់ត្នោត។ យើងពុំបានរកឃើញវត្ថុសិល្បៈអ្វីផ្សេងទៀតទេ។

នៅលើផ្ទៃទួលសម្បូរទៅដោយដើមត្នោត។ រីឯនៅជុំវិញទួលនេះវិញមានតែចម្ការសណ្តែកនិងវាលស្រែនៅជុំវិញ។



ទិដ្ឋភាពត្រពាំងរបស់ទួលស្តេចផ្អុំ



វត្ថុសិល្បៈដែលគរចោលនៅគល់ដើមត្នោត

## ២៦. ទួលវិហារចាស់

ទួលវិហារចាស់ ស្ថិតនៅមិនឆ្ងាយប៉ុន្មានពីទួលស្តេចផ្អុំ។ ទួលនេះមានគូទឹកព័ទ្ធជុំវិញ ដែលយើងមើលពុំឃើញនូវស្លាកស្នាមច្រកចូលទៅកាន់ទួលទេ ព្រោះមានសំណាបដែលប្រជាពលរដ្ឋស្ទូងស្រូវពាសពេញ

គូទឹកដែលព័ទ្ធជុំវិញទួលនេះ។ នៅលើទួល មានបល្ល័ង្កមួយ និងមានខឿនថ្មបាយក្រៀម ទំហំប្រហែល៤ម៉ែត្របួនជ្រុង។



បល្ល័ង្កដែលជាទម្របដិមានៅលើទួលវិហារ



ខឿនថ្មបាយក្រៀមនៅលើផ្ទៃទួលវិហារ

**២៧. គុកតូច**

គុកតូច ស្ថិតនៅក្នុងភូមិដូនតុំ ឃុំឈូកខ្សាច់។ គុកត្រូវបានសង់ឡើងនៅលើខឿន និងមានកំពែងថ្មបាយក្រៀម។ នៅលើផ្ទៃទួលសម្បូរទៅដោយបំណែកនៃថ្មចម្លាក់ អំពីថ្មភក់មានដូចជា ចម្លាក់ក្រឡោតទាប ផ្ដែរ(ផ្កាប់) ស៊ុមទ្វារ។

ចំណែកឯទិដ្ឋភាពខាងក្រៅវិញ គុកមានគូទឹកព័ទ្ធជុំវិញដែលមានច្រកចូលនិងមានថ្នាធំនៅទិសខាងកើត។ លក្ខណៈប្លង់របស់ប្រាសាទនេះ គឺមានលក្ខណៈដូចគ្នាទៅនឹងទួលតាមពេជដែរ គឺមានដើមស្លង់។

បើយើងពិនិត្យនៅលើផ្ទៃខាងលើទួល យើងឃើញមានរណ្ដៅកំណាយជ្រៅៗ មានព្រៃដុះពី លើ។ ជាពិសេសទៅទៀតប្រហែលជាមានបំណែកឬចម្លាក់ថ្មភក់ជាច្រើនទៀតដែលនៅកប់នឹងគម្ពោតព្រៃ។



ទិដ្ឋភាពគុកតូច



ខឿនប្រាសាទសង់ថ្មបាយក្រៀម



ថ្មមានចម្លាក់ក្រឡោតទាប



ចម្លាក់ក្រឡោតទេវរូបលើថ្មភក់កម្រប្រទះ




ប្លង់ទួលវិហារចាស់

## ២៨. ទួលយាយស្រី

ទួលយាយស្រី ស្ថិតនៅក្នុងឃុំឈូកខ្សាច់។ ទួលនេះគឺជាប្រាសាទដែលកសាងឡើងនៅសម័យអង្គរ មានគូទឹកព័ទ្ធជុំវិញ មានច្រកចូលពីទិសខាងកើត កំពែងសង់ពីថ្មបាយក្រៀម។ នៅផ្នែកខាងក្នុង មានបំណែកហោជាង ចំរឹងបង្អួច បំណែកសសរផ្តោប ស៊ុមទ្វារថ្មភក់ និងបំណែកថ្មបាយក្រៀមជាច្រើនដុំ។

ស្ថានភាពបច្ចុប្បន្ន ប្រាសាទនេះមានសភាពបាក់រលំនិងធ្លាប់មានចោរជីកគាស់កកាយ បំផ្លាញរកវត្ថុបុរាណ ធ្វើឱ្យយើងមើលមិនឃើញច្បាស់អំពីតួប៉មប្រាសាទនៅខាងក្នុងនោះទេ។ បន្ទាប់ពីមានការជីកបំផ្លាញលើទួល អ្នកស្រុកបាននាំគ្នាមកកាយមើលតួកណ្តាលឃើញព្រះពុទ្ធរូបផ្សេងៗជាច្រើនសាងពីវត្ថុធាតុផ្សេងៗគ្នាប្រហែលជាង១០០រូប ដែលបច្ចុប្បន្នតម្កល់ទុកនៅវត្តបារាយណ៍។



កំពែងថ្មបាយក្រៀមរបស់ទួលយាយស្រី



បំណែកហោជាងដែលធ្លាក់មកលើដី




ប្លង់ប្រាសាទយាយស្រី




ប្លង់ប្រាសាទយាយស្រី

## ២៩. វត្តខ្សាច់ល្អិត

វត្តខ្សាច់ល្អិត ស្ថិតក្នុងឃុំចុងដូង នៅក្នុងបរិវេណវត្ត មានទេពប្រណមចំនួន៦ ដែលឈរទល់ខ្នងគ្នា។ បដិមាទាំងត្រូវបានភ្ជាប់គ្នា ហើយមិនទាន់ធ្លាក់ចប់សព្វគ្រប់នៅឡើយទេ។ បដិមានេះកសាងឡើងអំពីថ្មភក់ ដែលបាត់ព្រះកេសហើយដែលជំនួសដោយវត្ថុធាតុដើមស៊ីម៉ង់ត៍វិញ។

នៅជុំវិញព្រះវិហារ មានដុំឥដ្ឋពាយប៉ាយ តែវាមិនមែនជាឥដ្ឋប្រាសាទបុរាណទេ ព្រោះវាមានទំហំតូចៗជាងឥដ្ឋប្រាសាទ។ នៅក្នុងរោងមួយ នៅក្នុងវត្ត មានទម្របដិមាមួយ ដែល មិនទាន់បានរំលីងដូចគ្នានឹងទេពប្រណម្យដែរ។



ចម្លាក់បដិមាទេពប្រណម្យទាំង៦



ថ្មភក់ដែលជាទម្របដិមានៅក្នុងវត្តខ្សាច់ល្អិត

## ៣០. វត្តស្រះកែវ

វត្តស្រះកែវស្ថិតនៅក្នុងភូមិគូ ឃុំចុងដូង។ ព្រះវិហាររបស់វត្តនេះចាប់កសាងរយៈពេល១ឆ្នាំហើយ ដែលសង់លើទួលប្រាសាទចាស់។ ស្លាកស្នាមចាស់ទួលប្រាសាទបង្ហាញឱ្យឃើញថា ប្រាសាទនេះមានគូទឹកព័ទ្ធជុំវិញ។ ឥដ្ឋប្រាសាទត្រូវបានប្រមូលយកទៅសង់សំណង់តូចៗនៅក្បែរនេះ។

មានបំណែកផ្តែរជាផ្នែកកណ្តាល ស្ថិតនៅខាងជើងព្រះវិហារ។ បំណែកផ្តែរឆ្លាក់ក្បាច់ចម្លាក់ជារូបព្រះឥន្ទ្រ ជិះលើក្បាលដំរី និងមានតោងាកចេញក្រៅខ្លាក់ជងផ្កា។ មានថ្មអឌ្ឍចន្ទ្រ ស្ថិតនៅខាងកើតជាប់ព្រះវិហារ ព្រមទាំងទម្រប់ដិមា និងដុំថ្មភក់ផ្សេងទៀត។ ថ្មទាំងនេះ គឺប្រមូលចេញពីទីតាំងព្រះវិហារសព្វថ្ងៃ។ មានថ្មបាយក្រៀមតិចតួចនៅលើដី ដែលអាចជាទីតាំងនៃ ប្រាសាទបុរាណ។

នៅខាងកើតចម្ងាយប្រមាណ១០០ ម៉ែត្រ មានស្រះមួយដែលជាស្រះបុរាណ (ស្រះខ្លាយ) ។


ព្រះវិហារកំពុងសាងសង់


ស្រះខ្លាយនៅភាគខាងកើត


បំណែកផ្តែរឆ្លាក់ព្រះឥន្ទ្រជិះដំរី


ទម្រប់ដិមា



ប្លង់វត្តស្រះកែវ

### ៣១ វត្តចុងដូង

វត្តចុងដូង ស្ថិតនៅក្នុងភូមិចុងដូង ឃុំចុងដូង។ នៅជុំវិញខឿននិងបរិវេណខាងក្រៅព្រះវិហារ យើងប្រទះឃើញមាន បល្ល័ង្កព្រះ, ក្អែនព្រះពុទ្ធបដិមា, បំណែកព្រះពុទ្ធប្រក់នាគ, ទម្រប់ដិមាដែលមាន

ប្រហោង២ ទម្រសីមា និងមានកំពូលចេតីយ ចំនួន២ដែលយើងពុំស្គាល់សម័យកាល។



ទម្របដិមាប្រើជាទម្រតោ



និងបល្ល័ង្គព្រះអំពីថ្មភក់



បល្ល័ង្គព្រះ និង ភ្នែនព្រះពុទ្ធរូប



កំពូលចេតិយ៍

## ៣២. ទួលភូមិក្តី

ទួលភូមិក្តី ស្ថិតនៅក្នុងភូមិចុងដូង ឃុំចុងដូង។ ទួលនេះមានគូទឹកព័ទ្ធជុំវិញ។ យើងមិនបានប្រទះឃើញសំណល់ថ្មបាយក្រៀមឬថ្មភក់ទេ លើកលែងតែដុំឥដ្ឋដែលគេតម្រៀបគ្នានៅគល់ដើមចន្ទីមួយ។ តាមរយៈព័ត៌មានរបស់ម្ចាស់ទួលបានបញ្ជាក់ឱ្យដឹងថា មានជនខិលខូចបានលួចជីកកកាយរកវត្ថុបុរាណជាញឹកញាប់។ សំណល់បល្ល័ង្គចំនួន៣ត្រូវបានគេយកទៅកប់ចោលដើម្បីកុំឱ្យអ្នកមកលួចបន្តទៀត។ ក្រៅពីនេះ មានត្រពាំងមួយទៀត នៅផ្នែកខាងលិចទួល។



កំពូលសន្ទឹកសីមានៅលើទួល



គំនរឥដ្ឋដែលគរនៅគល់ដើមចន្ទីលើទួល

## ៣៣. ទួលចម្ការដូង

ទួលចម្ការដូង ស្ថិតនៅក្នុងភូមិកំប៉ោយចាស់ ឃុំចុងដូង។ យើងបានទទួលព័ត៌មានថា កាលពីមុនទួល នេះ សម្បូរទៅដោយដុំឥដ្ឋនៅរាយបាយ លើផ្ទៃទួល។ ប៉ុន្តែតាមការចុះសិក្សាពិនិត្យជាក់ស្តែង មិនមានបំណែកថ្មបាយក្រៀមច្រើនទេ មានតែដុំថ្មមួយដុំប៉ុណ្ណោះ។ ការពិនិត្យស្ថានភាពទួលបង្ហាញឱ្យឃើញថា ទួលនេះប្រហែលជាមានគូទឹកព័ទ្ធជុំវិញ តែហាក់ដូចជាមិនមានស្លាកស្នាមគ្រប់គ្រាន់សម្រាប់បញ្ជាក់ឱ្យច្បាស់លាស់ទេ។ អ្វីដែលគួរចាប់អារម្មណ៍គឺគេធ្លាប់ជីកបានចំពួយ (គន្ធី)នៅទីនេះ។ រីឯបំណែកឥដ្ឋនៅលើទួលនេះ ត្រូវបានមនុស្សមួយចំនួនជីករទេះសេះ យកទៅជាទំនប់ភ្លឺស្រែ។



ទិដ្ឋភាពទួលមើលពីចម្ងាយ



ស្លាកស្នាមគូទឹក

## ៣៤. ទួលបល្ល័ង្គ

ទួលបល្ល័ង្គ ស្ថិតក្នុងភូមិជ័យមង្គល ឃុំបល្ល័ង្គ។ ទួលនេះជាទួលប្រាសាទបុរាណ។ យើងឃើញមានសំណល់ឥដ្ឋតិចតួច និងមានថ្មបាយក្រៀមដែលគេរៀបជាសាទ្បុំ។ យើងក៏រកឃើញជើងទម្រសីម៉ាសង់ពីថ្មបាយក្រៀមដែរ។



ទួលបល្ល័ង្គជ័យ



ទម្រសីម៉ាធ្វើពីថ្មបាយក្រៀម

## ៣៥. ប្រាសាទត្នោតជុំ[4] (គុកខាងលិច)

ប្រាសាទគុកខាងលិច ស្ថិតនៅក្នុងភូមិត្នោតជុំ[5] ឃុំត្នោតជុំ។ ប្រាសាទគុកខាងលិច

---

4 សូមអាន Lajonquière, Invenaire Descriptif des Monuments du Cambodge, Tome I, 1902, p. 210

សង់បែរមុខទៅទិសខាងជើង តួប្រាសាទរាងបួនជ្រុងស្មើ ប្រវែង៤,៥០ម៉ែត្រ។ លោក Lajonquière សន្និដ្ឋានថា ប្រាសាទត្នោតជុំខាងលិចគឺជាប្រាសាទដែលនៅស្អាត និងរក្សាទ្រង់ទ្រាយដើមបានល្អបំផុតក្នុងចំណោមប្រាសាទឥដ្ឋនានាក្នុងប្រទេសកម្ពុជា[6]។ មានសិលាចារឹកមួយរកឃើញនៅប្រាសាទនេះដែរ ដែលមានកាលបរិច្ឆេទនៅចុងសតវត្សទី១០នៃគ.ស.។

នៅមុខប្រាសាទ យើងសង្កេតឃើញមានស្នាទ្រោនី និងជើងទម្របដិមាដាក់តម្រៀបគ្នានៅខាងមុខប្រាសាទ។ នៅខាងក្រោយតួប្រាសាទនេះ មានសំណង់ថ្មបាយក្រៀមមួយបាក់បែកមួយ។ សសរពេជ្រប្រាសាទមានរាង៦ជ្រុង ដែលជាលក្ខណៈនៃរចនាបថសម័យអង្គរ។ មានផ្តែរមួយនៅរក្សាទ្រង់ទ្រាយដើម រចនាដោយក្បាច់លម្អផ្សេងៗ ដូចជា នៅកណ្តាលផ្តែរមានចម្លាក់ព្រះឥន្ទ្រជិះដំរី នៅអមដំរីមានតោ២ពាំ ឬខ្ជាក់ដងផ្កាជាកម្រងផ្កា ហើយនៅខាងចុងសងខាងផ្តែរមានសត្វតោ២ទៀត។


តួប្រាសាទត្នោតជុំខាងលិច (គុកលិច)


ទម្របដិមាដាក់តម្រៀបគ្នានៅមុខប្រាសាទ


ផ្តែររបស់ប្រាសាទត្នោតជុំខាងលិច (គុកលិច)


សំណង់ថ្មបាយក្រៀមនៅខាងក្រោយប្រាសាទ

[5] ក្នុងភូមិត្នោតជុំមានប្រាសាទ២គឺប្រាសាទត្នោតជុំខាងលិច (គុកលិច) និងប្រាសាទត្នោតជុំខាងជើង (គុកជើង ឬ គុកកំបុត)។

[6] Lajonquière, Invenaire Descriptif des Monuments du Cambodge, Tome I, 1902, p. 210




ប្លង់ប្រាសាទត្នោតជុំខាងលិច (គុកលិច)

### ៣៦. ប្រាសាទត្នោតជុំខាងជើង[7] (គុកជើង)

ប្រាសាទគុកខាងជើង ស្ថិតនៅក្នុងភូមិត្នោតជុំ ឃុំត្នោតជុំ។ ប្រាសាទនេះបែរមុខទៅ ទិសខាងកើត ស្ថិតនៅជាប់ដងស្ទឹងជីនិត ហើយស្ថិតនៅភាគអាគ្នេយ៍នៃគុកខាងលិច។ ប្រាសាទសង់ពីឥដ្ឋ រាងបួនជ្រុងស្មើ ទំហំ៦ម.។ នៅលើស៊ុមទ្វារគុក មានសិលាចារឹក២ដែលជាអក្សរនៅសម័យមុនអង្គរ។ សិលាចារឹកនៅលើស៊ុមទ្វារខាងត្បូង ចារក្នុងសម័យក្រោយអង្គរ ប្រហែលនៅសតវត្សទី១៥ ជាភាសាបាលី។ គេបានកោសលុបអក្សរសិលាចារឹកសម័យមុនអង្គរចោល ទើបចារសិលាចារឹកជាភាសាបាលីនេះ តាមក្រោយ។ ប្រាសាទនេះព័ទ្ធជុំវិញដោយគូទឹក ដែលមានធ្លានិងច្រកចូលនៅទិសខាងកើត។ ផ្តែរមានអក្សដងផ្ទួដែលឆ្លាក់ក្រេចជាបួនកង់ មានផ្ការំយោលដែលយើងអាចសន្និដ្ឋានបានថា ស្ថិតនៅក្នុងរចនាបថសម្បូរព្រៃគុក។

នៅផ្នែកខាងត្បូងលើជញ្ជាំងប្រាសាទមានរូបព្រះពុទ្ធឆ្លាក់លុងទៅលើជញ្ជាំងឥដ្ឋក្នុងកាយវិការអភ័យមុទ្រនៅក្នុងសតវត្សទី១៥ បន្ថែមនឹងការចារសិលាចារឹកថ្មីមួយទៀត។ ការឆ្លាក់លុងព្រះពុទ្ធបដិមានេះ គឺបានកែប្រែតួនាទីប្រាសាទនេះទៅជាចេតិយ៍វិញនៅក្នុងសម័យកាលនោះ។



ប្រាសាទត្នោតជុំខាងជើង (គុកខាងជើង)



ប្រាសាទត្នោតជុំខាងជើង (គុកខាងជើង)

[7] លោក Lajonquière (Inventaire Descriptif des Monuments du Cambodge, Tome I, 1902, p. 211) ហៅប្រាសាទនេះថា «គុកកំបុត, ប្រាសាទកំបុត (Prasat Kambot)»។



ប្លង់ប្រាសាទត្នោតជុំខាងជើង (គុកខាងជើង)

(ប្រភព : Lajonquière p. 212)




ប្លង់ប្រាសាទត្នោតជុំខាងជើង (គុកជើង)

គូដោយក្រុមការងារ

## ៣៧. ផ្តែរនិងទម្របដិមានៅការិយាល័យវប្បធម៌ស្រុកបារាយណ៍

តាមការពិនិត្យទៅលើក្បាច់ចម្លាក់លើដុំផ្តែរដែលតម្កល់នៅក្នុងការិយាល័យវប្បធម៌ស្រុកបារាយណ៍ យើងអាចសន្និដ្ឋានថា ផ្តែរនេះស្ថិតនៅក្នុងរចនាបថកំពង់ព្រះ ដោយសារយើងឃើញមានអក្សរដងផ្ទូ ក្បាច់ផ្កាភ្ញី ក្បាច់សន្ទឹកផ្កាភ្ញីនិងក្បាលសសរ។

រីឯទម្របដិមាវិញ យើងពុំអាចកំណត់សម័យកាលនោះបានទេ។

វត្ថុទាំងពីរខាងលើ ពុំមានប្រភពទីតាំងដើមនោះទេ។



ផ្តែរតម្កល់នៅការិយាល័យវប្បធម៌ស្រុកបារាយណ៍



ទម្របដិមានៅការិយាល័យវប្បធម៌ស្រុកបារាយណ៍

## ៣៨. វត្តបារាយណ៍ - តួបអ្នកតា ១២១

វត្តបារាយណ៍ ស្ថិតនៅក្នុងឃុំបារាយណ៍។ នៅក្នុងបរិវេណវត្ត មានគំនរថ្មភក់ដាក់នៅនឹងគល់ឈើមួយនៅភាគនិរតីនៃព្រះវិហារ។ បំណែកថ្មទាំងនោះមានដូចជា បំណែកហោជាង បល្ល័ង្កព្រះពុទ្ធបដិមា បំណែកស៊ុមទ្វារ បង្គោលសីមា និងថ្មអឌ្ឍចន្ទ្រ សង់ថ្មភក់។

នៅខាងកើតព្រះវិហារមានតូបអ្នកតាមួយ ដែលត្រូវបានគេហៅឈ្មោះថា អ្នកតា១២១។ នៅក្នុងតូបនេះ មានបំណែកកជើងបដិមាមួយជាប់ជាមួយនឹងជើងទម្រ។ ក្រៅពីនេះ មានបំណែកចម្លាក់ក្រឡោតត្រឹមចង្កេះចុះក្រោមនៃបដិមាមួយ (បើពិនិត្យទៅលើកេតនភណ្ឌនៃរូបនោះមានកាន់ដុំមូល អាចសន្និដ្ឋានថាជា ព្រះនរាយណ៍)។



គំនរថ្មភក់ដែលជាគ្រឿងបង្គុំប្រាសាទបុរាណ



រោងអ្នកតានៅខាងកើតព្រះវិហារ

## ៣៩. វត្តប្រាសាទ

វត្តប្រាសាទស្ថិតនៅក្នុងឃុំឈូកខ្សាច់។ យើងមានជំនឿថាទីតាំងព្រះវិហារប្រហែលជាទីតាំងប្រាសាទបុរាណមួយ ដោយសារមានសំណង់ខឿនអំពីថ្មបាសាល់ដែលគេប្រើជាខឿនព្រះវិហារ បច្ចុប្បន្ន។ នៅជុំវិញនេះ យើងប្រទះឃើញប្រភេទថ្មបាសាល់ផ្សេងទៀតព្រមទាំងថ្មកំពូលប្រាសាទ និងទម្របដិមាចំនួនពីរដែលគេដាក់ដាំដើមផ្កាលម្អក្នុងបរិវេណវត្ត។ ព្រះខ័ន្ធ ចំនួនពីរដែលបានដាក់តាំងនៅសាលាស្រុក បារាយណ៍ គឺបានយកចេញពីវត្តនេះ។



ខឿនព្រះវិហាអំពីថ្មបាសាល់



ខឿនព្រះវិហាអំពីថ្មបាសាល់



ថ្មកំពូលប្រាសាទ



និងទម្រលិង្គប្រើប្រាស់ធ្វើជាផើងផ្កា



រូបបំណែកបដិមា



បំណែកចម្លាក់នៅក្នុងរោងអ្នកតា

## ៤០.ប្រាសាទគុកនគរ[8]

ប្រាសាទគុកនគរបច្ចុប្បន្នស្ថិតក្នុងភូមិត្រដក់ពង ឃុំពង្រ ស្រុកតាំងគោក ខេត្តកំពង់ធំ[9]។ ប្រាសាទគុកនគរសង់ពីថ្មបាយក្រៀម មានតួកណ្ដាល ថែព័ទ្ធជុំវិញ លើកលែងតែគ្រឿងបង្គំប្រាសាទ ដូចជា មេទ្វារ ផ្ដែរ... ទើបសង់ពីថ្មភក់។

ចាស់ទុំមួយចំនួនដែលរស់ក្នុងភូមិបាននិយាយតៗគ្នាថា ក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ពួកខ្មែរក្រហមបានដុតប្រាសាទគុកនគរ ទើបបណ្ដាលឱ្យប្រាសាទនេះឡើងខ្មៅ ក្លាយជាពណ៌ត្នោតក្រម៉ៅ។

ប្រាសាទគុកនគរ សាងឡើងក្នុងសតវត្សទី១១ រាជ្យព្រះបាទសូរ្យវរ្ម័នទី១[10]។



ប្រាសាទគុកនគរមើលពីលើ

[8] ចាស់ៗក្នុងភូមិហៅថា «គុកនគរ» ប៉ុន្តែឯកសាររដ្ឋបាលសរសេរ «គុហ៍នគរ»។

[9] ក្នុងឆ្នាំ២០០៦ ប្រាសាទគុកនគរបច្ចុប្បន្នស្ថិតក្នុងភូមិត្រដក់ពង ឃុំពង្រ ស្រុកបារាយណ៍ ខេត្តកំពង់ធំ

[10] Aymonier, Le Cambodge I Le Royume Actuel, Paris, 1900, p. 346



ប្រាសាទគុកនគរមើលពីខាងជើង



តួកណ្ដាលប្រាសាទគុកនគរ




Fig. 119. — Prasat Kuk Nokor, n° 147. Plan.
(Échelle 1/500.)

ប្លង់ប្រាសាទគុកនគរ

(ប្រភព : Lajonquière, p. 205)

## សន្និដ្ឋាន

ជាសរុបមក យើងបានរកឃើញស្ថានីយបុរាណចំនួន៤០ ដែលបានចុះក្នុងអត្ថបទនេះ ក្នុងនោះរួមមាន៖ ប្រាសាទ, ទួលប្រាសាទ សាឡុម និងវិហារវត្តពុទ្ធសាសនា។ ចំនួនស្ថានីយទាំង៤០នេះ យើងមិនបានរាប់បញ្ចូលត្រពាំងបុរាណទេ។ ចំនួនស្ថានីយបុរាណក្នុងស្រុកបារាយណ៍នឹងកើនឡើងច្រើនប្រសិនបើយើងរាប់បញ្ចូលទាំងត្រពាំងបុរាណ។ យើងសង្កេតឃើញថាវត្តពុទ្ធសាសនាខ្លះសង់លើប្រាសាទបុរាណដែលពីមុននោះគេគោរពបូជាដល់ទេពព្រហ្មញ្ញសាសនា។ នៅតំបន់ខ្លះ គេយកប្រាសាទបុរាណមកកែច្នៃទៅជាសាឡុំ ដោយនៅក្នុងនោះមានព្រះពុទ្ធបដិមាមួយឬច្រើនទៅតាមលទ្ធភាពដែលគេអាចធ្វើទៅបាន ហើយពុទ្ធបដិមាខ្លះធ្វើពីបំណែកថ្មប្រាសាទបុរាណ។ នេះបង្ហាញពីប្រពៃណីមួយដែលខ្មែរនៅតែបន្តគោរពទីតាំងសក្តិសិទ្ធពីជំនាន់មួយទៅជំនាន់មួយទៀតដោយគ្រាន់តែកែប្រែទម្រង់ខ្លះ គឺពីព្រហ្មញ្ញសាសនាមកពុទ្ធសាសនាវិញ។ ការប្រើបំណែកថ្មប្រាសាទបុរាណសម្រាប់សាងសង់វិហារថ្មី បង្ហាញពីទំនាក់ទំនងនៃការគោរពតម្កល់ និងការបន្តប្រើធនធានដែលមានស្រាប់។ វាគឺជាអន្តរកម្មរវាងការផ្លាស់ប្តូរសាសនាមួយទៅសាសនាមួយទៀតនៅតែ បន្តដែលជាលក្ខណៈនៃអត្តសញ្ញាណវប្បធម៌ខ្មែរ។

ទាក់ទងនឹងការតាំងទីលំនៅដ្ឋានសម័យបុរាណតាមរយៈវត្ថុមានរបស់ស្ថានីយបុរាណ យើងសង្កេតឃើញថា ការតាំងទីលំនៅរបស់មនុស្សសម័យបុរាណមិនខុសពីការតាំងទីលំនៅសម័យបច្ចុប្បន្នប៉ុន្មានទេ។ វត្ថុមានស្ថានីយច្រើននៅតាមផ្លូវជាតិលេខ ៦។ ដូច្នេះហើយ យើងសង្ស័យថា ផ្លូវជាតិនេះប្រហែលជាផ្លូវសម័យបុរាណដែលគេប្រើប្រាស់យូរមកហើយ។ នេះជាការសន្និដ្ឋានដំបូងរបស់យើង ភស្តុតាងច្បាស់លាស់ណាមួយ ទាមទារឱ្យមានការសិក្សាស៊ីជម្រៅបន្ថែមទៀត។

ការសិក្សាឱ្យកាន់តែស៊ីជម្រៅថែមទៀតយើងនឹងអាចបកស្រាយអថ៌កំបាំងខាងលើ។ លក្ខណៈមួយដែល យើងកត់សម្គាល់ដែរគឺ ប្រាសាទមួយចំនួនមានទីតាំងនៅខាងឦសានភូមិ។ ការសាងសង់ប្រាសាទខ្មែរបុរាណទាក់ទងខ្លាំងនឹងទិស។ ទិសឦសានជាទិសទាក់ទងនឹងការចាប់កំណើតឡើងវិញ។ ការសាងសង់ប្រាសាទ នៅទិសខាងឦសានជាជំនឿមួយដែលគេគិតថា ប្រាសាទសង់ឡើងដើម្បីឧទ្ទិស និងគោរពបូជាដល់បុព្វការីជនដែលបានស្លាប់បាត់បង់ជីវិតទៅហើយ ឱ្យបានមកចាប់កំណើតសារជាថ្មីវិញ។

ស្ថានីយជាច្រើនស្ថិតនៅជិតទីទួលទំនាប ដែលមានប្រភពទឹក ដែលបញ្ជាក់ពីជ្រើសរើសទីតាំងរស់នៅរបស់ខ្មែរត្រូវមានសក្តានុពលសម្រាប់ការចិញ្ចឹមជីវិតផងនិងការគោរពប្រតិបត្តិសាសនាផង។ ការយល់ដឹងអំពីប្រពៃណីពីបុរាណ អាចជួយបកស្រាយអំពីយុទ្ធសាស្ត្រសេដ្ឋកិច្ចសង្គមរបស់ខ្មែរនៅសម័យបុរាណដែរ។

ការប្រមូលទិន្នន័យប្រវត្តិសាស្ត្រពីចាស់ទុំក្នុងភូមិស្រុកអាចជួយផ្តល់ចំណេះដឹងបន្ថែមអំពីប្រជាជនសម័យបច្ចុប្បន្នយល់ឃើញយ៉ាងណាចំពោះវត្ថុបុរាណ ឬការថែរក្សាតម្លៃនៃសម្បត្តិបុរាណទាំងនោះយ៉ាងណាដែរ។

ភស្តុតាងស្ថានីយដែលបានរកឃើញនៅក្នុងស្រុកបារាយណ៍ក៏បង្ហាញពីកាលវេលានៃការចាប់ផ្តើមរស់នៅរបស់មនុស្សក្នុងស្រុកបារាយណ៍ នេះដែរ។ ដោយសារស្ថានីយសម័យបុរេប្រវត្តិសាស្ត្រមិនបានរកឃើញ ការសន្និដ្ឋានជាបឋមថា ការតាំងទីលំនៅរបស់សហគមន៍ស្រុកបារាយបានចាប់ផ្តើមនៅសម័យមុនអង្គរ បន្តដល់សម័យអង្គរ សម័យកណ្តាល និងរហូតដល់បច្ចុប្បន្ន។ គួរឱ្យកត់សម្គាល់មួយទៀតដែរថា សហគមន៍ស្រុកបារាយណ៍នៅសម័យកណ្តាលបានជ្រើសរើសទីតាំងគោរពបូជាពីសម័យមុនអង្គរ ឬ សម័យអង្គរមកកែទម្រង់ ដោយសាងជាវិហារបែបពុទ្ធសាសនា ព្រមទាំងកែច្នៃបដិមាពីសម័យមុនៗមកជាបដិមាព្រះពុទ្ធវិញ។ ទួលវិហារពុទ្ធសាសនាខ្លះត្រូវបានគេកែពីទួលប្រាសាទបុរាណ ដោយហៅថា«សាទ្បុំ»។

# ឯកសារយោង


Aymonier, Etinne., Le Cambodge I Le Royume Actuel, Paris, 1900

Boisselier, Jean., Asie du Sud-Est : I. Le Cambodge, Paris, 1966, p. 151-152.

Lajonquière, E. Lunet., Inventaire Descriptif des Monuments du Cambodge, Tome I, 1902.

*មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ, «តារាងស្ថិតិប្រាសាទ ទួល ស្រះ វត្តបុរាណ» ឆ្នាំ២០១៩។*